ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី២៤ ខែ ៨ ឆ្នាំ២២
ក្រឡាបញ្ជី
Sanny

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ: ២០៥៩ អក
ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១
សាលក្រមលេខ: ៨១ (ត)
ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២

[redacted]

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២

ដោយមានសមាសភាពដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ២០៩៥ អក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ៖

១.ជនជាប់ចោទឈ្មោះ [redacted] លា ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted]ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] នាង (ស្លាប់) ម្ដាយឈ្មោះ [redacted] ទ្រព (រស់) ប្រពន្ធឈ្មោះ លឹម ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការគ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទ: ប៉ុនប៉ងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកគង់រាជ ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី៣ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.ជនជាប់ចោទឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិផ្លូវត្រី ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] មួង (រស់) ម្ដាយឈ្មោះ [redacted] អូន (រស់) នៅលីវ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការគ្មាន។ (គេចខ្លួន)

ជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិផ្លូវត្រី ឃុំថ្មគោល ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

- បានឃើញរបាយការណ៍លេខ: ៦២០ រប.ក ចុះថ្ងៃទី១៤-១២-២០២១ របស់អធិការដ្ឋាននគរបាលស្រុកល្វាឯម។

- បានឃើញកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី១៣-១២-២០២១ ។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ១៩០២ ដក.សស ចុះថ្ងៃទី១៤-១២-២០២១ ។
- បានឃើញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នលេខៈ ៥០៤៦ ដក.បឃខ ចុះថ្ងៃទី១៤-១២-២០២១។
- បានឃើញកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១៣.១២.២០២១។
- បានឃើញដីកាសម្រេចដាក់ជនត្រូវចោទឲ្យជាប់កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ លេខ ៥២២១ ចុះថ្ងៃទី២៤-១២-២០២១ ។
- បានឃើញកំណត់ហេតុស្តីពីការបើកពិនិត្យ ធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី២៧.០១.២០២២។
- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ ១៩៨ ដក.សព ចុះថ្ងៃទី១៧-០២-២០២២ ។
- បានឃើញដីកាដំណោះស្រាយលេខៈ ២៣០ ដក.ដស ចុះថ្ងៃទី២៣-០២-២០២២ ។
- បានឃើញដីកាបង្គាប់ឲ្យដោះលែងលេខ ៥២២០ ដកបដល ចុះថ្ងៃទី២៤-០២-២០២២ និងលេខ ៧២៣ ចុះថ្ងៃទី២៣-០២-២០២២ ។
- បានឃើញដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះលេខៈ ២៨៣ ដក.ចត ចុះថ្ងៃទី០៩-០៣-២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។
- បានឃើញលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៥២៨៧/២២ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី០២-០៣-២០២២។
- បានឃើញលិខិតលេខ១៩៣/ប្រ.គម/កណ ចុះថ្ងៃទី១៨.០៧.២០២២ ស្តីពីការចាត់តាំងមេធាវី។

## នាពេលសវនាការ

- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លា នៅចៅក្រមស៊ើបសួរថាៈ សមត្ថកិច្ចឃាត់ខ្លួនៗកាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង១១ ថ្ងៃត្រង់ ខ្លួនបានជិះម៉ូតូទៅទិញថ្នាំញៀនពីឈ្មោះ [redacted] ណារិន តាមរយៈទូរស័ព្ទមិនចាំលេខ ពេលនោះវាប្រាប់ឱ្យខ្លួនទៅយកនៅផ្ទះវា ពេលនោះខ្លួនទៅដល់វាក៏ប្រាប់ខ្លួនតាមរយៈទូរស័ព្ទឱ្យខ្លួនទៅសួរម្តាយវាឈ្មោះ [redacted] អូន ថាមកយកឥវ៉ាន់ ហើយគាត់ប្រាប់ថា រកមើលទៅ រកឃើញយកខ្លួនឯងទៅ ហើយខ្លួនក៏ផ្ញើលុយទៅឱ្យគាត់ចំនួន ២០០០០៛ (ពីរម៉ឺនរៀល) ទុកនៅគាត់ ហើយខ្លួនក៏យកថ្នាំញៀន ០១កញ្ចប់ រួចហើយមីងឈ្មោះ [redacted] អូន គាត់ពុំបានដឹងថាឥវ៉ាន់អីទេ។ ខ្លួនទៅយកថ្នាំញៀនពីផ្ទះរបស់ឈ្មោះ [redacted] ណារិន ចំនួន០៣ដង និងនៅតាមផ្លូវ០១ដង ដោយយកពីឈ្មោះ ណារិន ចំនួន០២ដង ហើយទៅយកពីផ្ទះចំនួន០២ដង គឺជួបម្តាយគាត់ឈ្មោះ [redacted] អូន ហើយផ្ញើលុយ និងត្រីទុកនៅម្តាយគាត់។ ខ្លួនស្គាល់ឈ្មោះ [redacted] ណារិន ចំនួន០១ឆ្នាំមកហើយ តាមរយៈធ្វើការបេះស្វាយជាមួយគ្នា ហើយខ្លួនទើបតែដឹងថា ឈ្មោះ [redacted] ណារិន លក់ថ្នាំញៀនរយៈពេល ០៣ ទៅ០៤ខែ នេះ ហើយខ្លួនដឹងព្រោះខ្លួនធ្លាប់ជក់ថ្នាំញៀនជាមួយវា នៅក្នុងចំការស្វាយ។ ខ្លួនទិញយកមកប្រើប្រាស់មិនមែនទិញយកមកលក់បន្តទេ។ ពេលខ្លួនបានថ្នាំញៀនហើយ ខ្លួនត្រលប់ទៅវិញ ស្រាប់តែសមត្ថកិច្ចចាប់ខ្លួនតែម្តង។ សមត្ថកិច្ចរឹបអូស ម៉ូតូ០១គ្រឿង ថ្នាំញៀន០១កញ្ចប់ និងទូរស័ព្ទ ០១គ្រឿង។ ពេលនោះសមត្ថកិច្ចនាំខ្លួនទៅ



Scanned with CamScanner

តាមចាប់ដល់ផ្ទះឈ្មោះ [redacted] ណារិន រកឃើញថ្នាំញៀន ០៨ កញ្ចប់ទៀត។ ខ្លួនចេះជក់ថ្នាំញៀនរយៈពេល ៤ ទៅ ៥ ខែនេះប៉ុណ្ណោះ។ ខ្លួនសូមសំណូមពរតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំផង។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាៈ ក្រោយពីបានសាកសួរដេញដោលរួចមក តំណាងអយ្យការរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ១៩៨ ដក.សព ចុះថ្ងៃទី១៧-០២-២០២២ ទុកជាបានការដដែល និងសំណូមពរផ្តន្ទាទោសតាមច្បាប់។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថាៈ ដោយសារកូនក្តីរបស់ខ្លួនឈ្មោះ [redacted] លា បានសារភាពទទួលស្គាល់កំហុសនៅគ្រប់ដំណាក់កាលទាំងអស់ ថាខ្លួនពិតជាបានប្រើប្រាស់គ្រឿងញៀនពិតប្រាកដមែន។ បើយោងតាមកំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ របស់មន្ត្រីនគរបាលយុត្តិធម៌ បានបង្ហាញថា កូនក្តីខ្លួនមានកម្រិតវប្បធម៌ទាបត្រឹមថ្នាក់ទី៥ថ្មី ជាហេតុធ្វើឲ្យគាត់ពុំសូវមានការយល់ដឹងពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន ងាយនឹងត្រូវបានគេអូសទាញ ទើបធ្វើឲ្យសម្រេចចិត្តប្រើប្រាស់វា។ ហើយក្នុងនោះ គាត់ខ្លួនឯងក៏ជាជនរងគ្រោះដែលកើតចេញពីការប្រើប្រាស់នេះផងដែរ។ ម៉្យាងវិញទៀត គាត់បានចូលរួមសហការជាមួយសមត្ថកិច្ចក្នុងការចង្អុលបង្ហាញពីសកម្មភាព និងគោលដៅដែលបានប្រព្រឹត្តបទល្មើស ស្តែងឲ្យឃើញពីឆន្ទៈក្នុងការទទួលស្គាល់កំហុសរបស់គាត់។ ហើយកូនក្តីរបស់ខ្លួនក៏ពុំធ្លាប់បានផ្តន្ទាទោសពាក់ព័ន្ធនឹងបទល្មើសណាមួយដែរ។ ដូចនេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ខ្លួនសំណូមពរសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យពិចារណាបន្ធូរបន្ថយទោស ដោយសម្រេចកាត់តំរឹមទោស ដើម្បីឲ្យកូនក្តីខ្លួន មានឱកាសកែប្រែខ្លួនឲ្យល្អ និងចូលមករស់នៅក្នុងសង្គមវិញ។ ដោយឡែកចំពោះកូនក្តីរបស់ខ្លួនឈ្មោះ [redacted] ណារិន ដោយសារតែគាត់មិនបានចូលមកផ្តល់ចម្លើយជូនតុលាការ ដូច្នេះ ខ្លួនសុំមិនធ្វើសេចក្តីសន្និដ្ឋាន ដោយទុកសិទ្ធិឲ្យតុលាការសម្រេចតាមច្បាប់។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី
- ក្រោយពីបានពិនិត្យភស្តុតាងនានា
- ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

១-ជនជាប់ចោទឈ្មោះ [redacted] លា បានឆ្លើយសារភាពថាៈ សមត្ថកិច្ចឃាត់ខ្លួនៗ កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង១១ ថ្ងៃត្រង់ ខ្លួនបានជិះម៉ូតូទៅទិញថ្នាំញៀនពីឈ្មោះ [redacted] ណារិន ចំនួន ២០០០០(ពីរម៉ឺន)រៀល បានថ្នាំ០១កញ្ចប់ ពេលខ្លួនបានថ្នាំញៀនហើយ ខ្លួនត្រលប់ទៅវិញ ស្រាប់តែសមត្ថកិច្ចចាប់ខ្លួនតែម្តង។ ខ្លួនទៅយកថ្នាំញៀនពីផ្ទះរបស់ឈ្មោះ [redacted] ណារិន ចំនួន០៣ដង និងនៅតាមផ្លូវ០១ដង ដោយយកពីឈ្មោះ ណារិន ចំនួន០២ដង ហើយទៅយកពីផ្ទះចំនួន០២ដង គឺជួបម្តាយគាត់ឈ្មោះ [redacted] អូន ហើយផ្ញើលុយ និងត្រីទុកនៅម្តាយគាត់។ ខ្លួនស្គាល់ឈ្មោះ [redacted] ណារិន ចំនួន០១ឆ្នាំមកហើយ តាមរយៈធ្វើការបេះស្វាយជាមួយគ្នា ហើយខ្លួនទើបតែដឹងថា ឈ្មោះ [redacted] ណារិន លក់ថ្នាំញៀនរយៈពេល ០៣



Scanned with CamScanner

ទៅ០៤ខែ នេះ ហើយខ្លួនដឹងព្រោះខ្លួនធ្លាប់ជក់ថ្នាំញៀនជាមួយវា នៅក្នុងចំការស្វាយ។ ខ្លួនទិញយកមកប្រើប្រាស់មិនមែនទិញយកមកលក់បន្តទេ។ ដែលចម្លើយនេះ មានភាពស៊ីសង្វាក់គ្នាទៅនឹងវត្ថុតាង ដែលដកហូតបាន បញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] លា ពិតជាបានប្រព្រឹត្តអំពើប៉ុនប៉ងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងឈ្មោះ [redacted] ណារិន ពិតជាបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

២-តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១៣.១២.២០២១ របស់អធិការដ្ឋាននគរបាលស្រុកល្វាឯម ចាប់យកវត្ថុតាងពីឈ្មោះ [redacted] អូន (ម្តាយបង្កើតរបស់ឈ្មោះ [redacted] ណារិន) និងឈ្មោះ [redacted] លា មានម្សៅក្រាមសថ្លាសង្ស័យជាសារធាតុញៀន ចំនួន ០៩កញ្ចប់ (០៦កញ្ចប់ធំ តូច០៣កញ្ចប់) ។

តាមកំណត់ហេតុស្តីពីការបើកពិនិត្យ ធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី២៧.០១. ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ឃើញថា វត្ថុតាងជាម្សៅក្រាមពណ៌សថ្លាចំនួន០៩កញ្ចប់ ដោយ ០៨កញ្ចប់ ជារបស់ជនជាប់ចោទឈ្មោះ [redacted] ណារិន មានទម្ងន់ ២៣,២២ក្រាម និង០១កញ្ចប់តូច ជារបស់ជនជាប់ចោទឈ្មោះ [redacted] លា មានទម្ងន់០,២១ក្រាម សរុបទាំងអស់២៣,៤៣ក្រាម។

យោងតាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៥២៨៧/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០២-០៣-២០២២ ការសន្និដ្ឋានៈ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅថ្លា ឈ្មោះ មេតំហ្វេតាមីន, ដែលមានកម្រិតភាពសុទ្ធ ៧៣,៤៥% នៃទម្ងន់សរុប, មេតំហ្វេតាមីន ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

សារធាតុញៀនប្រភេទមេតំហ្វេតាមីនដែលដកហូតបានមានទម្ងន់សរុប ២៣.៤៣ ក្រាម ឯលទ្ធផលកោសលវិច័យគ្រឿងញៀនមានកម្រិតភាពសុទ្ធ៧៣.៤៥% ដូច្នេះត្រូវយកទម្ងន់សរុបស្មើនិង ២៣.៤៣ ក្រាម គុណនឹង កម្រិតភាពសុទ្ធ ៧៣.៤៥% ចែកនឹង ១០០ =១៧.២០ ក្រាម ឃើញថាថ្នាំញៀនដែលដកហូតបានមានបរិមាណសុទ្ធ ១៧.២០ ក្រាម ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] លា ដែលបានធ្វើសកម្មភាពទិញថ្នាំញៀនពីជនជាប់ចោទឈ្មោះ [redacted] ណារិន ដើម្បីប្រើប្រាស់ ប៉ុន្តែមិនទាន់បានប្រើប្រាស់ផង ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនបាន ស្តែងឡើងដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើប៉ះពាល់ ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់សុខភាពខ្លួនឯង ហើយអំពើនោះទៀតសោតជាអំពើផ្ទុយនឹងច្បាប់ និងកំណត់ថាជាបទៈ ប៉ុនប៉ងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌ ៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ណារិន ដែលបានធ្វើសកម្មភាពលក់ថ្នាំញៀន ស្តែងឡើងដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើប៉ះពាល់ ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកដទៃ ហើយអំពើនោះទៀតសោតជាអំពើផ្ទុយនឹងច្បាប់ និងកំណត់ថាជាបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៥ ចំណុច ៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

៥-ជនជាប់ចោទឈ្មោះ [redacted] លា និងឈ្មោះ [redacted] ណារិន ជានីតិជន មានស្មារតីយល់ដឹង និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសព្រហ្មទណ្ឌ ដែលកើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត។

៦-ពុំមានភស្តុតាងជាឯកសារឬសេចក្តីបញ្ជាក់ណាមួយពីសាក្សីជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ដែលបានបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] លា និងឈ្មោះ [redacted] ណារិន ជាជនកើតវិបល្លាសស្មារតីដែលធ្វើឲ្យបាត់បង់នូវការយល់ដឹងខុសត្រូវរបស់ខ្លួន ដែលជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដូចមានបញ្ញត្តិក្នុងមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌនោះទេ។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] លា ភេទប្រុស អាយុ៣៧ឆ្នាំ ពីបទៈ ប៉ុនប៉ងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកគង់រាជ ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌ ៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ២៥ឆ្នាំ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកគង់រាជ ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៥ ចំណុច ៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩-តាមការប្តឹងសុំរបស់តំណាងអយ្យការមកតុលាការឱ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លា ពីបទៈ ប៉ុនប៉ងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងឈ្មោះ [redacted] ណារិន ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤៥ កថាខណ្ឌ៣ និងមាត្រា៤០ កថាខណ្ឌ៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ តុលាការយល់ឃើញថាៈ ការប្តឹងសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ គប្បីតុលាការសម្រេចតាមការប្តឹងសុំ។

១០-ជនជាប់ចោទឈ្មោះ [redacted] ណារិន ដែលបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហើយបានគេចខ្លួន គឺជាចេតនាគេចវេសពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដើម្បីធានាដល់ការអនុវត្តទោស ក៏ដូចជារក្សាសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈនិងសន្តិសុខសង្គម គប្បីតុលាការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ២៥ឆ្នាំ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១១-វត្ថុចាប់យកមានៈ ម្សៅក្រាមពណ៌សថ្លា សង្ស័យជាសារធាតុញៀនខុសច្បាប់ ចំនួន០៩កញ្ចប់ វេចខ្ចប់ដាក់ស្រោមសំបុត្រ ពណ៌សតូច មួយបិទជិតគ្មានលេខកូដ, ម៉ូតូចំនួន០១គ្រឿង ម៉ាក់សង់ទ្រឹមសេ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ កណ្តាល 1W-7055 (មិនប្រក្រតី), ទូរស័ព្ទចំនួន ០៣គ្រឿង ម៉ាកសាំសុង ពណ៌ស (មិនប្រក្រតី), ម៉ាក Huawei ពណ៌ក្រហម (មិនប្រក្រតី) និងម៉ាកណូគា ពណ៌ក្រហម (មិនប្រក្រតី), លោហៈពណ៌លឿងមានដូចជា ខ្សែដៃចំនួន០១, ចិញ្ចៀនចំនួន ០៥វង់, បណ្តោងខ្សែកចំនួន ០២ និងក្រវិលចំនួន០១គូ, ក្រដាសវេលុយរឹងមួយសន្លឹក ជញ្ជីងថ្លឹងចំនួន០១ និងសម្ភារៈប្រើប្រាស់ថ្នាំញៀនមួយចំនួន ជាវត្ថុតាងដែលជាប់ពាក់ព័ន្ធនឹងបទល្មើសខាងលើ គប្បីតុលាការសម្រេចរឹបអូស។



Scanned with CamScanner

# ហេតុដូច្នេះសម្រេច

**១**-ផ្តន្ទាទោស:

ក.ជនជាប់ចោទឈ្មោះ [redacted] លា ភេទប្រុស អាយុ៣៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០៤ (បួន) ខែ តែទោសនេះត្រូវព្យួរការអនុវត្តមូលទោស។

ពីបទៈ ប៉ុងប៉ងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកគង់រាជ ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ.ជនជាប់ចោទឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០៦ (ប្រាំមួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល ។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកគង់រាជ ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៥ ចំណុច ៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២**-ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ២៥ឆ្នាំ។

**៣**-វត្ថុចាប់យកមានៈ ម្សៅក្រាមពណ៌សថ្លា សង្ស័យជាសារធាតុញៀនខុសច្បាប់ ចំនួន០៩ កញ្ចប់ វេចខ្ចប់ដាក់ស្រោមសំបុត្រ ពណ៌សតូច មួយបិទជិតគ្មានលេខកូដ, ម៉ូតូចំនួន០១គ្រឿង ម៉ាក់សង់ទ្រីម សេ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ កណ្តាល 1W-7055 (មិនប្រក្រតី), ទូរស័ព្ទចំនួន ០៣គ្រឿង ម៉ាកសាំសុង ពណ៌ស (មិនប្រក្រតី), ម៉ាក Huawei ពណ៌ក្រហម (មិនប្រក្រតី) និងម៉ាកណូគា ពណ៌ក្រហម (មិនប្រក្រតី), លោហៈពណ៌លឿងមានដូចជា ខ្សែដៃចំនួន០១, ចិញ្ចៀនចំនួន ០៥វង់, បណ្តោងខ្សែកចំនួន ០២ និងក្រវិលចំនួន០១គូរ, ក្រដាសវេលុយរឹងមួយសន្លឹក ជញ្ជីងថ្លឹងចំនួន០១ និងសម្ភារៈប្រើប្រាស់ថ្នាំញៀនមួយចំនួន ត្រូវរឹបអូស។

**៤**-សាលក្រមនេះជំនុំជម្រះជាសាធារណៈ កំបាំងមុខជនជាប់ចោទទាំងពីរនាក់ ។

" ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ "

| | | | |
|---|---|---|---|
| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| ហត្ថលេខា និងត្រា: | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា: |

[redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្តាល ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]